# សេចក្តីជូនដំណឹងស្តីពី
# ការស្វែងរកអ្នកផ្តល់សេវាកម្មសម្រាប់ការរៀបចំ និងអនុវត្តគម្រោងបង្កើតប្រាក់ចំណូល
# ក្រោមក្របខណ្ឌនៃមូលនិធិទ្រទ្រង់ជីវភាពសហគមន៍

| | | |
|---|---|---|
| ខេត្ត ពោធិ៍សាត់ | ស្រុក ក្រគរ | ឃុំ ក្បាលត្រាច |

ប្រវត្តិសង្ខេប ៖

ក្នុងឆ្នាំ ២០០៩ នេះ ក្រុមប្រឹក្សាឃុំ ក្បាលត្រាច បានទទួលការគាំទ្រមូលនិធិទ្រទ្រង់ជីភាពសហគមន៍ ក្រោមក្របខណ្ឌ នៃគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប តាមរយៈក្រសួងមហាផ្ទៃ សម្រាប់គាំទ្រលើការរៀបចំ និងអនុវត្តគម្រោងអាទិភាពនានា ដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ ។យោងតាមលទ្ធផលនៃការចាត់អាទិភាពគម្រោង និងតាមលក្ខខណ្ឌនៃការប្រើប្រាស់ មូលនិធិទ្រទ្រង់ជីវភាពសហគមន៍ ក្រុមប្រឹក្សាឃុំបានសម្រេចជ្រើសរើសគម្រោងបង្កើតប្រាក់ចំណូលមួយចំនួន ដើម្បីធ្វើការរៀបចំ និងអនុវត្តនៅក្នុង ២០០៩ នេះ ។

ហេតុនេះ ដើម្បីរៀបចំ និងអនុវត្តគម្រោងបង្កើតប្រាក់ចំណូលទាំងនោះ ក្រុមប្រឹក្សឃុំ ក្បាលត្រាច សូមប្រកាសអញ្ជើញអ្នកផ្តល់សេវាកម្ម ដែលមានការចាប់អារម្មណ៍ ដើម្បី មករៀបចំសំណើគម្រោង និងអនុវត្តគម្រោងបង្កើតប្រាក់ចំណូល ដូចមានរៀបរាប់ខាងក្រោមនេះ ៖

| ល.រ | គម្រោង | ចំនួនគម្រោង | ចំនួនអ្នកទទួលផល ក្នុង១គម្រោង | ទីតាំងគម្រោង | តម្លៃអតិបរិមា ១គម្រោង |
|---|---|---|---|---|---|
| ១ | ចិញ្ចឹមក្របីមេជាលក្ខណៈគ្រួសារ | ០១ | ១៦គ្រួសារ | ត្រពាំងស្នាច់ | USD១០,០០០.០០ |
| ២ | ចិញ្ចឹមក្របីមេជាលក្ខណៈគ្រួសារ | ០១ | ១៦គ្រួសារ | ស្រែឫស្សី | USD១០,០០០.០០ |
| ៣ | ចិញ្ចឹមក្របីមេជាលក្ខណៈគ្រួសារ | ០១ | ១៦គ្រួសារ | សំរោង | USD១០,០០០.០០ |
| | សរុប | ០៣ | ៤៨គ្រួសារ | ០៣ភូមិ | USD៣០,០០០.០០ |

| | |
|---|---|
| រយៈពេលអនុវត្តគម្រោង ៖ | |
| អ្នកដែលអាចមានសិទ្ធិចូលរួម ៖ | អង្គការមិនមែនរដ្ឋាភិបាល ឬភ្នាក់ងារឯកជនដែលបានចុះបញ្ជីស្របច្បាប់ និងមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តគម្រោងដូចខាងលើ។ |
| ទីកន្លែងពេលដែលអាចទទួលឯកសារពាក់ព័ន្ធ ៖ | សាលាឃុំ ក្បលត្រាច ឬ ការិយាល័យក្រុមសម្របសម្រួលជីវភាពសហគមន៍ ( CLFT )<br>ចាប់ពីថ្ងៃផ្សព្វផ្សាយព័ត៌មាននេះ នៅរាល់ម៉ោងធ្វើការ |
| កាលបរិច្ឆេទទទួលសំណើគម្រោង ៖ | ៣១/១២/២០០៩ ដល់ ១៣/០១/ ២០១០ |
| ទីកន្លែងទទួលសំណើគម្រោង ៖ | សាលាឃុំ ក្បាលត្រាច |
| កាលបរិច្ឆេទវាយតម្លៃសំណើគម្រោង ៖ | ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ |

កំណត់សម្គាល់ ៖

- ចំពោះសំណើគម្រោងនីមួយៗគណៈកម្មការលទ្ធកម្មឃុំនឹងធ្វើការវាយតម្លៃលើសំណើគម្រោងផ្នែកបច្ចេកទេស និងសំណើតម្លៃប៉ាន់ស្មានគម្រោងតាមរយៈការផ្តល់ពិន្ទុ ។ គណៈកម្មការលទ្ធកម្មនឹងធ្វើការជ្រើសរើសយកសំណើគម្រោងណាដែលល្អជាងគេ មានន័យថាគឺជាគម្រោងដែលទទួលបានពិន្ទុសរុបខ្ពស់ជាងគេ ដើម្បីពិចារណាក្នុងការចុះកិច្ចសន្យាអនុវត្ត ។

- ព័ត៌មានលម្អិតផ្សេងៗសូមទាក់ទងមក ៖
    - លោក ដួង សារិន ទូរស័ព្ទលេខ ០១២ ៨៨០ ៦០៩
    - លោក ងួន សារុន ទូរស័ព្ទលេខ ០៩២ ៨៦០ ៣៨៥

ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩

**មេឃុំ**

ដួង - សារិន